**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## សារជូនចំពោះជនរួមជាតិកម្ពុជា

- សូមក្រាបថ្វាយបង្គំសម្ដេចសង្ឃរាជ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ
- បងប្អូនជនរួមជាតិទាំងអស់ជាទីគោរពស្នេហា

ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នេះ គឺជាទិវាប្រវត្តិសាស្ត្រថ្មីមួយទៀតរបស់ជាតិកម្ពុជាទាំងមូល ដោយគណៈកម្មការអន្តររដ្ឋាភិបាលសម្រាប់ការការពារបេតិកភ័ណ្ឌវប្បធម៌អរូបីយរបស់អង្គការយូណេស្កូ បានអនុម័តយល់ព្រមចុះ **ល្ខោនខោល** ចូលក្នុងបញ្ជីបេតិកភ័ណ្ឌអរូបីយនៃមនុស្សជាតិ នៅក្នុងឱកាសកិច្ចប្រជុំលើកទី ១៣ ក្នុងទីក្រុងព័រល្វីស សាធារណរដ្ឋម៉ូរីស។ នេះគឺជាមោទនភាពថ្មីមួយទៀតសម្រាប់ប្រជាពលរដ្ឋនិងព្រះរាជាណាចក្រកម្ពុជា ដែល **ល្ខោនខោល** របស់កម្ពុជា ត្រូវបានទទួលស្គាល់ថាជាស្នាដៃសិល្បៈបុរាណដ៏វិសេសវិសាលអស្ចារ្យ និងមានតំលៃជាសកល។

**ល្ខោនខោល** គឺជាបេតិកភ័ណ្ឌខ្មែរទី ៥ ហើយ ដែលបានទទួលនូវឋានៈដ៏ឧត្តុង្គឧត្តម បន្ទាប់ពីការបញ្ចូល **ប្រាសាទសំបូរព្រៃគុក** ក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក កាលពីថ្ងៃ ៨ ខែ កក្កដា ឆ្នាំ ២០១៧ កន្លងទៅ។ បេតិកភ័ណ្ឌផ្សេងទៀត ដែលត្រូវបានបញ្ចូលទៅក្នុងបញ្ជីសម្បត្តិវប្បធម៌ពិភពលោក រួមមាន **ប្រាសាទអង្គរវត្ត** នៅឆ្នាំ ១៩៩២ **របាំក្បាច់បុរាណខ្មែរ** (របាំព្រះរាជទ្រព្យ) នៅឆ្នាំ ២០០៣ និង**ប្រាសាទព្រះវិហារ** នៅឆ្នាំ ២០០៨។

ការដាក់ **ល្ខោនខោល** ចូលក្នុងបញ្ជីបេតិកភ័ណ្ឌសម្បត្តិវប្បធម៌អរូបីយនៃមនុស្សជាតិ តាមសេចក្ដីសម្រេចរបស់គណៈកម្មការអន្តររដ្ឋាភិបាលសម្រាប់ការការពារសម្បត្តិបេតិកភ័ណ្ឌវប្បធម៌អរូបីយរបស់អង្គការយូណេស្កូ គឺជាលទ្ធផលនៃកិច្ចប្រឹងប្រែងដ៏យូរអង្វែង និងការពុះពារយ៉ាងសកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងការគាំទ្រយ៉ាងផុលផុសពីសិល្បៈករ អង្គការ សមាគមន៍ សង្គមស៊ីវិល ដែលធ្វើការក្នុងវិស័យសិល្បៈវប្បធម៌ និងការគាំទ្រលើកទឹកចិត្តពីមហាជនទូទៅ និងប្រជាជនកម្ពុជាទាំងមូល ។

ការបញ្ចូល **ល្ខោនខោល** ទៅក្នុងបញ្ជីអរូបីយនៃមនុស្សជាតិ នាពេលនេះ គឺជាការរួមចំណែកធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់ព្រះរាជាណាចក្រកម្ពុជាកាន់តែល្បីសុះសាយទូទាំងពិភពលោក ហើយធ្វើឲ្យកម្ពុជាក្លាយជាតួអង្គកាន់តែលេចធ្លោរថែមទៀត នៅលើវេទិកាបេតិកភ័ណ្ឌពិភពលោក។

ក្នុងឱកាសដ៏មហាប្រសើរនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាតសម្ដែងនូវអំណរព្រះគុណដ៏ជ្រាលជ្រៅបំផុតថ្វាយ **ព្រះករុណាព្រះមហាក្សត្រ ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ដែលព្រះអង្គតែងតែប្រោសប្រទាននូវការគាំទ្រដ៏ពេញទំហឹងជានិច្ច ចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីបុព្វហេតុជាតិ និងមាតុភូមិយើង។

ខ្ញុំសូមថ្លែងអំណរគុណ និងវាយតំលៃខ្ពស់ចំពោះការប្រឹងប្រែងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមការដឹកនាំរបស់លោកជំទាវ ភឿង សកុណា ដែលបានពុះពារជំនះគ្រប់ការលំបាករហូតសម្រេចបាននូវការចុះ **ល្ខោនខោល**ចូលក្នុងបញ្ជីបេតិកភ័ណ្ឌវប្បធម៌អរូបីយនៃមនុស្សជាតិនៅថ្ងៃនេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសផងដែរ ជូនចំពោះបណ្តាប្រទេសជាមិត្ត អង្គការយូណេស្កូ និងឥស្សរជនទាំងឡាយដែលបានទទួលស្គាល់នូវតំលៃដ៏អស្ចារ្យជាសកលនៃ **ល្ខោនខោល** របស់ព្រះរាជាណាចក្រកម្ពុជា ហើយបានចូលរួមគាំទ្រសំណើរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់ស្នាដៃសិល្បៈបុរាណដ៏វិសេសវិសាលរបស់កម្ពុជានេះ ទៅក្នុងបញ្ជីបេតិកភ័ណ្ឌវប្បធម៌អរូបីយនៃមនុស្សជាតិ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងទឹកចិត្តរីករាយឥតឧបមា ខ្ញុំព្រះករុណាខ្ញុំ សូមចែករំលែកនូវសមិទ្ធផលដ៏ធំធេងជាមោទនាភាពជាតិដ៏ខ្ពង់ខ្ពស់នេះ ជាមួយនឹងព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ និងជនរួមជាតិកម្ពុជាគ្រប់រូប ដែលបានគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ខ្ញុំព្រះករុណាខ្ញុំ ដើម្បីសុខសន្តិភាព ការអភិវឌ្ឍ និងបុព្វហេតុជាតិមាតុភូមិ។

ខ្ញុំសូមអំពាវនាវដល់សាធារណជន និងជនរួមជាតិកម្ពុជា មេត្តាបន្តចូលរួមលើកតម្កើងតម្លៃបេតិកភ័ណ្ឌវប្បធម៌ និងថែរក្សាការពារបេតិកភ័ណ្ឌជាតិកម្ពុជា។

ដើម្បីអបអរសាទរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ខ្ញុំសូមណែនាំគ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយជាមួយគ្នានេះសូមអំពាវនាវដល់ជនរួមជាតិកម្ពុជាគ្រប់រូប សូមរួមគ្នាចូលរួមអបអរសាទរតាមការវាយគង ទូងស្គរ ទះប៉ោត គោះត្រដោក និងតាមគ្រប់មធ្យោបាយដែលខ្លួនមាន នៅម៉ោង ១០ យប់ នាថ្ងៃទី ៣០ ខែ វិច្ឆិកា នៅគ្រប់ទីកន្លែងសាធារណៈសំខាន់ៗ រួមទាំងទីវត្តអារាមផងដែរ។

ខ្ញុំសូមសំណូមពរផងដែរដល់គ្រប់បណ្តាញផ្សព្វផ្សាយទាំងអស់ ចូលរួមសហការផ្សព្វផ្សាយព្រឹត្តការណ៍ជាប្រវត្តិសាស្ត្រនេះឲ្យបានទូលំទូលាយ និងអធិកអធមជាទីបំផុត។

សូមសម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជនរួមជាតិទាំងអស់ បានប្រកប និងប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃពុធ ៦ រោច ខែ កត្តិក ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**ហ៊ុន សែន**